00637292 E23

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ញត្តិរបស់ អៀង សារី ស្នើសុំការណែនាំអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្ដម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូ ឧត្ដារ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

ឯកសារទទួល

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24/01/2011

ម៉ោង (Time/Heure): 15:55

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យអនុម័តសេចក្តីណែនាំសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលសវនាការជំនុំជម្រះសំណុំរឿង ០០២ ។ មេធាវីការពារក្តីទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា រួមទាំង អវតក ផងដែរ ។ ដោយសារភាពខុសគ្នាខាងនីតិវិធីរវាង អវតក និង តុលាការកម្ពុជាដទៃទៀត ព្រមទាំងទំហំ និងភាពស្មុគស្មាញនៃរឿងក្តី នោះការណែនាំគឺត្រូវការចាំបាច់ នៅមុនការចាប់ផ្តើមសវនាការជំនុំជម្រះក្តី ដើម្បីធានាថាការចូលរួមរបស់គេគឺសមស្របទៅតាមតួនាទីដែលមានតែមួយគត់របស់ពួកគេនៅក្នុងដំណើរការនីតិវិធី ។ ប្រសិនបើគ្មានការណែនាំនេះទេ នោះសិទ្ធិជាសារវន្តរបស់លោក អៀង សារី ក្នុងការទទួលបាននូវសមភាពនៃមធ្យោបាយតទល់ក្តី និងការទទួលបាននូវការជំនុំជម្រះក្តីក្នុងពេលវេលាសមរម្យ នឹងទទួលរងនូវការប៉ះពាល់ជាពុំខានឡើយ ។ បញ្ហានេះត្រូវតែលើកយកមកពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងធ្វើឡើងនៅខែមីនា ឬខែមេសា ឆ្នាំ២០១១[1] ខាងមុខនេះ ដើម្បីឱ្យភាគីទាំងអស់បញ្ចេញទស្សនៈរបស់ពួកគេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

## I ច្បាប់នៅជាធរមាន

### ក. សមភាពនៃមធ្យោបាយតទល់ក្តី

១. អនុលោមទៅតាមមាត្រា ៣៣ថ្មី នៃច្បាប់បង្កើត អវតក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវធានាថា "ការជំនុំជម្រះក្តីត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ..."[2]។ មាត្រានេះក៏បានតម្រូវឱ្យ អវតក អនុវត្តយុត្តាធិការ "ស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ។

២. អនុលោមតាមវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសា

---

[1] សារអេឡិចត្រូនិកពីអ្នកនាង Susan Lamb អ្នកសម្របសម្រួលជាន់ខ្ពស់របស់តុលាការ ផ្ញើជូនក្រុមការពារ ក្តី អៀង សារី កម្មវត្ថុ: ការទំនាក់ទំនងទៅភាគីទាំងអស់ ជួសមុខឱ្យអង្គជំនុំជម្រះសាលាដំបូង-ក្រុមការពារ អៀង សារី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ។

[2] បញ្ជាក់បន្ថែម ។

មញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍នៅចំពោះមុខ ហើយត្រូវរក្សាបានតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ...[3]។ សិទ្ធិទទួលបានការជម្រះក្តីដោយយុត្តិធម៌ រួមបញ្ចូលផងដែរនូវ សិទ្ធិទទួលបាននូវសមភាពនៃមធ្យោបាយតទល់ក្តី។ សមភាពនៃមធ្យោបាយតទល់ក្តី គឺជា "គោលការណ៍ច្បាប់ដែលសហមេធាវីការពារក្តី និង សហព្រះរាជអាជ្ញាត្រូវមានសមភាពក្នុងកិច្ចនីតិវិធី ដើម្បីធានាថាការអនុវត្តកិច្ចដំណើរការនីតិវិធីតុលាការមានភាពយុត្តិធម៌"[4] ។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណី ០០១ បានបញ្ជាក់ថា "ុមូលដ្ឋាននៃគោលការណ៍នេះ ត្រូវបានទទួលស្គាល់នៅក្នុងវិធានផ្ទៃក្នុង..."[5]។ គោលការណ៍នេះមានលក្ខណៈសំខាន់ជាសារវ័ន្តចំពោះលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន រួមទាំង ICCPR[6] និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[7] ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា អវតក ត្រូវតែគោរព[8] ។

**ខ. សិទ្ធិទទួលបានការជំនុំជម្រះក្តីក្នុងពេលវេលាសមរម្យ**

៣. អនុលោមតាមមាត្រា ៣៥(គ)ថ្មី នៃច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

---

[3] បញ្ជាក់បន្ថែម ។

[4] *ករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* សំណុំរឿង ០០១/១៨/៧-២០០៧-អវតក, សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់សារណា ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារ D288/6.90, ERN: 00345178-00345180 នៅកថាខណ្ឌទី ៤។

[5] ដូចខាងលើ ។

[6] អនុម័ត និងបើកចំហរសម្រាបចុះហត្ថលេខា ផ្តល់សច្ចាប័ន្ទ និងព្រមព្រៀងដោយសេចក្តីសម្រេចលេខ 2200A(XXI) របស់មហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ដែលចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៧៦ អនុលោមតាមមាត្រា ៤៩។ អនុលោមតាមមាត្រា ១៤(១) "ជនគ្រប់រូបត្រូវមានភាពស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី ។ " ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តី ដែលមានសមត្ថភាព ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងបទល្មសព្រហ្មទណ្ឌ ឬ លើសិទ្ធិ ករណីកិច្ចក្នុងរឿងក្តីរដ្ឋប្បវេណី..." ។

[7] មាត្រា ១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស "មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យនិងឥតលម្អៀង ពិនិត្យរឿងក្តីជាសាធារណៈនិងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទល្មើសព្រហ្មទណ្ឌ ។

[8] សូមមើលរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩ មាត្រា ៣១ ។ មាត្រានេះតម្រូវថាតុលាការកម្ពុជា "ត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ" ។

"នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា សមស្របតាមមាត្រា ១៤ នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយឆ្នាំ ១៩៥៦...គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយពេលវេលា..."។

៤. អនុលោមតាមមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ ("ICCPR") "ក្នុងសម្រេចចោទប្រកាន់មកលើពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា ដោយស្មើគ្នាយ៉ាងពេញលេញ:...គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយពេលវេលា..." ។

៥. អនុលោមតាមវិធាន ២១(៤) នៃវិធានផ្ទៃក្នុង "ការសម្រេចលើការនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ។

## គ. តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី

៦. អនុលោមតាមមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា:

បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។ ដើម្បីទទួលការជួសជុលបានព្យនកម្មត្រូវតែ:

- ជាផលវិបាកផ្ទាល់នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន ។

ព្យសនកម្មអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត ។

៧. អនុលោមតាមមាត្រា ២៣(១) នៃវិធានផ្ទៃក្នុងចែងថា "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖ ក)ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង ខ) ទាមទារសំណងផ្លូវចិត្ត និងសម្ភារភាពដូចមាន ចែងនៅក្នុងវិធាន *២៣ស្ទួនបួន*" ។

00637296



**ឃ. តួនាទីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងទំនាក់ទំនងរបស់ពួកគេជាមួយមេធាវីដទៃទៀតតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

៨. អនុលោមតាមមាត្រា *១២ស្ទួនពីរ* ចែងថា

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធានាឱ្យមានប្រសិទ្ធិភាពអំពីការរៀបចំ ការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់តាំងពីដំណាក់កាលជំនុំជម្រះតទៅ ដែលធ្វើឱ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឱ្យការជំនុំជម្រះប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អវតក ។

[...]

៥. មុខងារសំខាន់ៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលទាំង:

ក) ការតំណាងឱ្យផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ ដូចដែលមានចែងនៅក្នុងវិធាន ២៣(១) និង(២) នៃវិធានផ្ទៃក្នុង ។

ខ) ការទទួលខុសត្រូវជាចុងក្រោយទៅកាន់តុលាការ សម្រាប់ការតស៊ូមតិ យុត្តិសាស្ត្រទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការអំពីផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលរួមគ្នាជាក្រុមតែមួយនោះ ចាប់តាំងពីដំណាក់កាលជំនុំជម្រះតទៅ

៦. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំអស់ ត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីផ្តល់ការគាំទ្រដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតំណាងផលប្រយោជន៍ឱ្យបណ្តុំនៃដើមបណ្តឹងរដ្ឋប្បវេណីដែលរួមគ្នាជាក្រុមតែមួយ ។ ការគាំទ្រដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចរួមបញ្ចូលទាំងការដាក់សារណាដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សី និងកិច្ចនីតិវិធីផ្សេងៗទៀត ។ ដោយអនុលោមតាមវិធាន ១២ស្ទួនពីរ (៥)(ខ) ការគាំទ្រនេះត្រូវមានការព្រមព្រៀងគ្នារវាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើការសម្របសម្រួលសកម្មភាពទាំងឡាយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមវិធីផ្តល់ការគាំទ្រនេះ ។

## II. អំណះអំណាង

៩. លោក អៀង សារី មានសិទ្ធិជាសារវ័ន្តក្នុងការទទួលបាននូវសមភាពនៃមធ្យោបាយតទល់ក្តី និងត្រូវបានជំនុំជម្រះក្នុងពេលវេលាសមរម្យ។ សិទ្ធិទាំងនេះនឹងត្រូវបានប៉ះពាល់ ប្រសិនបើការណែនាំមិនត្រូវបានអនុម័ត នៅមុនការចាប់ផ្តើមនៃសវនាការជំនុំជម្រះក្តី ដើម្បីបញ្ជាក់ពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេនោះ ។ ការណែនាំនេះនឹងជួយដល់ភាគីទាំងអស់នៃដំណើរការនីតិវិធី រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ ដូចដែលក្រុមតាមដានការជំនុំជម្រះក្តីនៅអង្គជំនុំជម្រះវិសាមញ្ញ អង្គការគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ាន (Asian International Justice Initiative) បានរកឃើញអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ ថា៖

> ចេញពីទស្សនទានរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេចក្តីណែនាំពីតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីខ្វះខាតភាពច្បាស់លាស់ (ព្រមទាំងកម្រិតនៃការរំពឹងទុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការអនុវត្តយន្តការនៃការជួសជុលសំណងដោយតុលាការ) បានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីអស់ជំនឿទុកចិត្តទៅលើដំណើរការនីតិធី និងបានខកចិត្តដោយការរំលោភរំពានដែលបង្កឡើងដោយការកាត់បន្ថយជាជាយថាហេតុនូវសិទ្ធិរបស់មេធាវីរបស់ពួកគេ[9] ។

### ក. ការណែនាំត្រូវតែអនុម័ត ដើម្បីការពារការសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបាននូវសមភាពនៃមធ្យោបាយតទល់ក្តី

១០. អនុលោមតាមវិធាន ២៣(១) ""គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖ ក)ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ <u>ដោយគាំទ្រដល់ការចោទប្រកាន់</u> និង ខ) ទាមទារសំណងផ្លូវចិត្ត និងសម្ភារភាព..."[10]។ ប្រសិនបើខ្លឹមសាររបស់វិធាននេះមិនត្រូវបានបកស្រាយត្រឹមត្រូវទេ នោះសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុង

---

[9] Michelle Staggs Kelsall និងអ្នកដទៃទៀត,, បទពិសោធន៍ពីការជំនុំជម្រះក្តី "ឌុច" KRT TRIAL MONITORING GROUP, ASIAN JUSTICE INITIATIVE (Staggs) ខែធ្នូ ទំព័រទី ២៨ ។

[10] បញ្ជាក់បន្ថែម ។

ការទទួលបាននូវសមភាពនៃមធ្យោបាយតទល់ក្តី អាចត្រូវបានគេរំលោភបំពាន[11] ។ ដូចដែលបានទទួលស្គាល់ដោយអង្គជំនុំជម្រះក្នុងករណី ០០១ "សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងនីតិវិធីព្រហ្មទណ្ឌ រួមទាំងសិទ្ធិប្រឈមនឹងអាជ្ញាធរចោទប្រកាន់តែប៉ុណ្ណោះ។ ដូច្នេះហើយ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិគាំទ្រ ឬ ជួយដល់អយ្យការដូចដែលកំពុងអនុវត្តនេះ តួនាទីរបស់ពួកគេនៅក្នុងការជំនុំជម្រះនេះ មិនត្រូវប្រែក្លាយទៅជាព្រះរាជអាជ្ញាបន្ថែមទៀតបានទេ"[12]។ ដូចដែលបានទទួលស្គាល់ដោយអ្នកធ្វើអធិប្បាយក្នុងករណី ០០១ "ជាក់ស្តែង ការណែនាំអនុវត្តដែលទាក់ទងទៅនឹងការកំណត់និយមន័យនៃសញ្ញាណនៃ "ការគាំទ្រដល់ការចោទប្រកាន់" ដូចមានចែងនៅក្នុងវិធាន ២៣(១) និងកម្រិតដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចសួរសាក្សីនានា ហើយជាផលទួទៅ នឹងមានផលប្រយោជន៍ដល់ភាគីទាំងអស់"[13]។

១១. ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ៖

> ស្ទើគ្រប់យុត្តាធិការដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ជនរងគ្រោះមានឱកាសចូលរួមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេនៅក្នុងការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ ដែលនាំឲ្យពួកគេក្លាយ

---

[11] គោលការណ៍សមភាពគ្នានៃការតតាំងរឿងក្តី គឺមានសារៈសំខាន់ជាសារវ័ន្តក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មដែលមានទំហំធំធេង ដោយសារតែមានការដាក់គំនាបដើម្បីវិនិច្ឆ័យទោស ដោយអាជ្ញាធរចោទប្រកាន់ និងទិន្នការជាប្រវត្តិសាស្ត្រក្នុងការនិយាយសម្រាលពីតួនាទីនៃការការពារក្តី ។ ប៉ុន្តែនៅ អវតក ការអនុវត្តគោលការណ៍នេះកាន់តែស្មុគស្មាញថែមទៀត បង្កឡើងដោយការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ដោយបានផ្លាស់ប្តូរតុល្យភាពនៃអំណាចរវាងគូប្រឆាំងនៃរចនាសម្ព័ន្ធបីភាគី ដែលរួមមានសិទ្ធិរបស់ដើមបណ្តឹងរដ្ឋបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេ..." Staggs នៅទំព័រទី២២ ។

[12] *ករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* ០០១/១៨-០៧-២០០៧/អវតក/អជសង, សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងការណែនាំស្តីពីការសាកសួរជនជាប់ចោទ, អ្នកជំនាញ និងសាក្សី ដែលត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩, E72/3, ERN: 00387022-00387047 ("សេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បណី ក្នុងការដាក់សេចក្តីសន្និដ្ឋានផ្តន្ទាទោស") នៅកថាខណ្ឌ២៦។

[13] Staggs នៅទំព័រទី៣៧ ។ សូមមើលផងដែរការអត្ថាធិប្បាយរបស់ James P. Bair, ពីចំនួនអ្នកស្លាប់ដល់ចំនួនអ្នកដែលរស់រានមានអាយុ: ការចូលរួមរបស់ជនរងគ្រោះនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, 31 HAWAII L. REV. 507, 526 (2009): "លុះត្រាតែវិធានផ្ទៃក្នុងត្រូវបានកំណត់និយមន័យ បញ្ជាក់បន្ថែម... បើមិនដូច្នេះទេភាសាដែលមានន័យទូលទូលាយបែបនេះបង្កឲ្យមាន ហានិភ័យដែលដើមបណ្តឹងរដ្ឋប្បវេណីអាចមាន ឬត្រូវបានគេយល់ថាជាតួនាទីដែលស្របគ្នា ដែលបានថ្កោលទោសដោយតុលាការសម្ញេងទៀត" ។

ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តី ។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី (*partie civile* ជាភាសាបារាំង) ជាទូទៅជនរងគ្រោះ មានសិទ្ធិដឹកនាំ និងដេញដោលភស្តុតាង ប៉ុន្តែ អាចធ្វើបានតែពាក់ព័ន្ធជាមួយការទាមទារសំណង ប្រឆាំងទៅនឹងជនជាប់ចោទ ប៉ុណ្ណោះ[14]។

ដូចដែលអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានពន្យល់៖

> នៅក្នុងយុត្តាធិកាជាច្រើនដែលអនុវត្តតាមប្រព័ន្ធដើមបណ្តឹងរបស់បារាំង ជនរងគ្រោះមានសិទ្ធិចូលរួមនៅក្នុងការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ ដើម្បីផ្តល់នូវមធ្យោបាយបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាពដើម្បីស្នើសុំនូវសំណងពីជនចាប់ចោទ ។ ជាលទ្ធផល ការជំនុំជម្រះមានគោលបំណងពីរយ៉ាង មួយដើម្បីកំណត់សម្រេចពីពិរុទ្ធភាព ឬគ្មានពិរិទ្ធភាព របស់ជនជាប់ចោទ និងដើម្បីប្រកាសអំពីទោស ក្នុងករណីដែលរកឃើញថាមានពិរុទ្ធភាព និងម្យ៉ាងទៀតដើម្បីធានាសំណង តាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណីដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានគិតគូរយ៉ាងច្បាស់អំពីលទ្ធភាពក្នុងការឱ្យមានកិច្ចដំណើរការនីតិវិធីចំនួនពីរតែម្តងជាមួយគ្នា គឺមួយសម្រាប់នីតិវិធីព្រហ្មទណ្ឌ និងមួយទៀតសម្រាប់ការទាមទារសំណងរដ្ឋប្បវេណី[15] ។

១២. ដូចមានចែងក្នុងវិធាន២៣(១) តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអានដើម្បីបញ្ជាក់អត្ថន័យថាដើមបណ្តឹងរដ្ឋប្បវេណីអាចគាំទ្រ កសព ក្នុងតួនាទីរបស់ខ្លួនជាអ្នកការពារផលប្រយោជន៍ទូទៅរបស់ជនរងគ្រោះ[16]។ វាមិនអាចមានន័យថាជាទូទៅដើមបណ្តឹងរដ្ឋប្បវេណីចាំតែគាំទ្រ កសព (ដោយតាំងខ្លួនជា "សហព្រះរាជអាជ្ញាទី២") ក្នុងការអនុវត្តការទទួលខុសត្រូវរបស់

---

[14] Brianne N. McGonigle, *មនុស្សនាក់សម្រាប់តម្លៃនៃមនុស្សម្នាក់: (Two for the Price of One:* ការប៉ុនប៉ងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីដាក់បញ្ចូលនូវ *Retributive and Restorative Justice Principles*, 22 Leiden J. Int'l L. 127, 137-38 (2009) ("McGonigle") (បញ្ជាក់បន្ថែម) ។

[15] សេចក្តីសម្រេចលើសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់សេចក្តីសន្និដ្ឋានផ្តន្ទាទោស នៅកថាខណ្ឌទី ១៨ (បញ្ជាក់បន្ថែម) ។

[16] ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូង ទទួលស្គាល់ថា៖"អាជ្ញាធរចោទប្រកាន់ក៏ការពារផលប្រយោជន៍យុត្តិធម៌ផងដែរ និងមានតួនាទីអនុវត្តបណ្តឹងអាជ្ញានៅក្នុងផលប្រយោជន៍ទូទៅរបស់សង្គម។ ផលប្រយោជន៍របស់សង្គមទាំងមូល និងផលប្រយោជន៍យុត្តិធម៌ គឺរួមបញ្ចូលទាំងផលប្រយោជន៍ទូទៅរបស់ជនរងគ្រោះនៃបទល្មើសដែលត្រូវចោទប្រកាន់ជាចាំបាច់"។ ដូចជើងទំព័រខាងលើ, កថាខណ្ឌទី២០។ (គូសបញ្ជាក់បន្ថែម)។

ខ្លួនដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ[17] ។ ការយល់ដូច្នេះចំពោះវិធាននេះ គឺមិនស្របទៅនឹងច្បាប់កម្ពុជា ឬក៏បទដ្ឋានយុត្តិធម៌អន្តរជាតិ ដែលធានាថាជនជាប់ចោទត្រូវតែទទួលបានការប្រព្រឹត្តដោយយុត្តិធម៌ ហើយសិទ្ធិរបស់គេក្នុងការទទួលបានភាពស្មើគ្នានៃការតតាំងក្តី ត្រូវតែគោរព ។

១៣. ការធ្វើវិសោធនកម្មវិធានផ្ទៃក្នុង[18] ដែលតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីតំណាងដោយសហមេធាវីនាំមុខរបស់ខ្លួននោះ មិនបានដោះស្រាយនូវភាពស្មើគ្នានៃមធ្យោបាយការពារក្តី ដែលត្រូវបានបង្កើតឡើងឡើយ ប្រសិនបើវិធាន២៣(១) ត្រូវបានគេបកស្រាយជាលក្ខណៈទូទៅ ។ ប្រសិនបើវិធាននេះមិនត្រូវបានគេបកស្រាយដោយមានការដាក់កំណត់ព្រំដែនរបស់វាទេ នោះមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅតែមានអនុភាពជា "ព្រះរាជអាជ្ញាទី២" ដដែល ។ម្យ៉ាងវិញទៀត សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅតែត្រូវការគាំទ្រពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតទាំងតាមរយៈ "ការដាក់សារណាផ្ទាល់មាត់ និងសារណាជាលាយលក្ខណ៍អក្សរ ការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សី និងកិច្ចនីតិវិធីដទៃទៀត[19]" ។ ពិតណាស់ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ អាចស្តាប់ចម្លើយសាក្សីនីមួយៗ ។ ដើម្បីជាផលប្រយោជន៍សមភាពនៃមធ្យោបាយការពារក្តី អង្គជំនុំជម្រះសាលាដំបូង ត្រូវតែបញ្ជាក់ពីតួនាទីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

### ខ. សេចក្តីណែនាំត្រូវតែអនុម័តដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលមួយដែលសមរម្យ

១៤. លោក អៀង សារី មានសិទ្ធិជាសារវ័ន្តដើម្បីទទួលបានការជំនុំជម្រះក្តីក្នុងពេលវេលាសមស្រប[20]។ សិទ្ធិនេះអាចត្រូវបានគេរំលោភ ប្រសិនបើការណែនាំនេះមិនត្រូវបានគេអនុម័តនៅមុនសវនាការជំនុំជម្រះក្តី ដើម្បីធានាថាភាគីទាំងអស់យល់ច្បាស់អំពីវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹង

---

[17] វិធាន៨៧(១)។

[18] សូមលើវិធានធាន១២ ស្ទួន(៦)។

[19] វិធានធាន១២ ស្ទួន(៦)។

[20] សូមមើលច្បាប់ស្តីពីការបង្កើត អវតក, មាត្រា៣៥ថ្មី (គ), វិធាន២១(៤), មាត្រា៣(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

រដ្ឋប្បវេណីទេនោះ ។ ពេលវេលាក្នុងសវនាការជំនុំជម្រះមិនគួរខ្ជះខ្ជាយទៅលើការដោះស្រាយបញ្ហាបែបនេះឡើយ ។

១៥. អ្នកអត្ថាធិប្បាយលើសំណុំរឿង០០១ តែងតែរិះគន់ដើមបណ្ដឹងរដ្ឋប្បវេណីថាបានសួរសំណួរក្រៅវិសាលភាពនៃការត្រួតពិនិត្យ និងចោទសួរសំណួរច្រំដែលៗ[21]។ នៅក្នុងសំណុំរឿង០០១ មានការជជែកវែកញែកទាក់ទងនឹងវិសាលភាព ដែលអាចទទួលយកបាននៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបញ្ហានេះបានពន្យាពេលសវនាការ និងធ្វើឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើពហិការមិនចូលរួមក្នុងដំណើរការនីតិវិធី[22]។ ការដែលថាមានក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីច្រើនក្រុម បានធ្វើឱ្យមានជម្លោះរវាងរវាងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗគ្នា ឬក៏មានទស្សនៈផ្សេងគ្នា ទាក់ទងនឹងតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយករណីនេះក៏អាចនាំឱ្យមានការភ័ន្តច្រឡំ និងការពន្យាពេលផងដែរ[23]។

១៦. ក្នុងសំណុំរឿង០០១ មានដើមបណ្ដឹងរដ្ឋប្បវេណីតែ៩០នាក់ប៉ុណ្ណោះក្នុងចំណោមក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំង៤ក្រុម[24]។ ក្នុងសំណុំរឿង០០២ មានដើមបណ្ដឹងរដ្ឋប្បវេណី

---

[21] សូមមើល Michael Saliba, ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អវតក, សេចក្ដីសង្ខេប, ព្រឹត្តិបត្រអ្នកឃ្លាំមើលតុលាការ,ចុះថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ២០០៩("Saliba"),ទំព័រទី៣,សូមចូលទៅគេហទំព័រhttp://cambodiatribunal.org/images/CTM/ctm_blog_11-6-2009.pdf: "ភាពខ្វះការសម្របសម្រួលក្នុងក្រុម តែងតែនាំ ទៅដល់ការសួរសំណួរច្រំដែលៗ"។ សូមមើលផងដែរ Staggs នៅទំព័រទី៣ "ក្ដីកង្វល់ចុងក្រោយទាក់ទងនឹងការដំណាងដើម បណ្ដឹងរដ្ឋប្បវេណី គឺជាយុទ្ធសាស្ត្ររៀបចំពេលវេលារបស់មេធាវីព្រោះមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហាក់បីដូចជា សួរសំណួរច្រំដែលៗជាញឹកញាប់។ ក្នុងសប្ដាហ៍ទី៩ អង្គជំនុំជម្រះសាលាដំបូង បានដាក់ពេលវេលាកំណត់ចំពោះភាគីដែលសួរសំ ណួរ ប៉ុន្តែបញ្ហានេះ មិនបានឈប់កើតឡើងនោះទេ"។ សូមមើលទំព័រទី៣៩ ផងដែរ។

[22] សូមមើល Saliba, ទំព័រទី៣។

[23] សូមមើល Staggs នៅទំព័រទី៣៣៖ "ការខ្វះធនធាន និងការសម្របសម្រួលទូទៅ មានន័យថា ការបំពេញភារកិច្ចរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទូទាំងសំណុំរឿង០០១ គឺច្របូកច្របល់គ្នា។ ខណៈពេលដែលមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនសន្និដ្ឋានថាតួនាទីរបស់ពួកគេនៅក្នុងតុលាការ គឺភាគច្រើនលើសលប់ដើម្បីគាំទ្រការចោទប្រកាន់" មេធាវីមួយចំនួនទៀតបានសង្កត់នូវតួនាទីរបស់ពួកគេជាសម្លេងនៃទស្សនៈ និងក្ដីកង្វល់របស់កូនក្ដីពួកគេទៅវិញ។ ជាច្រើនលើកច្រើនសារ ករណីនេះធ្វើឱ្យមេធាវីបន្តសំនួរមួយហើយមួយទៀតដោយផ្អែកតាមតម្រូវការរបស់កូនក្ដីម្នាក់ៗរបស់ពួកគេតែប៉ុណ្ណោះទោះបីជានៅពេលដែលសំណួរខ្លះមិនទាក់ទងនឹងសំណុំរឿងក៏ដោយ។ ផ្ទុយទៅវិញមេធាវីដែលព្យាយាមគាំទ្រការចោទប្រកាន់យ៉ាងច្រើនលើសលប់ជួនកាលហាក់បីដូចជាធ្វើខ្លួនជាសហព្រះរាជអាជ្ញាទី២ មិនមែនត្រឹមតែផ្ដល់ការគាំទ្រតែមួយមុខប៉ុណ្ណោះទេ"។

[24] ដូចដើងទំព័រខាងលើ,ទំព័រទី២៨។

ចំនួន២,១២៣នាក់[25]។ បញ្ហាដែលបានកើតឡើងក្នុងសំណុំរឿង០០១ នឹងរឹតតែមានភាពធ្ងន់ធ្ងរជាងមុនទៀតក្នុងសំណុំរឿង០០២ ។ ការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីត្រូវតំណាងដោយបណ្តុំមេធាវីនាំមុខតែមួយក្រុមនោះ[26] គឺជាជំហានមួយឆ្ពោះទៅការធ្វើឱ្យប្រសើរឡើងនូវបញ្ហាដែលបានលើកឡើងខាងលើ ប៉ុន្តែនឹងមិនអាចដោះស្រាយបានបញ្ហាទាំងនោះបានទេ[27]។ ភាពមិនច្បាស់លាស់នៅតែកើតមានដដែល។ វិធាន១២ ស្ទួន(៦) អនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់ការគាំទ្រសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ការគាំទ្រទាំងនេះអាចរួមបញ្ចូលទាំង "ការដាក់សារណាផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ការស្តាប់ចម្លើយកូនក្តីរបស់ខ្លួន និងសាក្សី និងកិច្ចនីតិវិធីផ្សេងៗទៀត"។ វិធាននេះហាក់បីដូចជាមិនបានហាមឃាត់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីច្រើននាក់ មិនឱ្យស្តាប់ចម្លើយសាក្សីតែម្នាក់ឡើយ។

**គ. មតិយោបល់ដើម្បីជាការពិចារណាក្នុងអនុម័តសេចក្តីណែនាំ**

១៧. ដោយសារតែ អវតក ជាតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង អាចត្រូវបានដឹកនាំដោយនីតិវិធីកម្ពុជា ដើម្បីបង្កើតសេចក្តីណែនាំមួយដែលសមស្របចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អវតក ក៏អាចត្រូវបានណែនាំដោយតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ ព្រោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏បានអនុញ្ញាឱ្យមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី ហើយបានដោះស្រាយសំណុំរឿងដែលមានវិសាលភាព និងភាពស្មុគស្មាញស្រដៀងគ្នានឹងសំណុំរឿងនៅ អវតក ផងដែរ។

១៨. នីតិវិធីកម្ពុជា គឺមានលក្ខណៈសក្តិសមជាពិសេសព្រោះ "វាជារឿងយុត្តិធម៌ណាស់ក្នុងការអះអាង

---

[25] *ករណី អៀង សារី* ០០២/១៩-១២-២០០៩-អវតក/កសចស, ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D427, ERN: 00604508-00605246, កថាខណ្ឌទី១២។

[26] សូមមើលវិធាន១២ ស្ទួន។

[27] Staggs, ទំព័រទី៧ "មិនថាមានការកែប្រែអ្វីចំពោះគម្រោងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ និងក្នុងសំណុំរឿងនៅពេលអនាគតទេ ចៅក្រមនៅ អវតក ប្រហែលជាចង់ចេញសារាចរណ៍ណែនាំអនុវត្តទាក់ទងនឹងការចូលរួមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលជំនុំជម្រះ។ សំនួរមូលដ្ឋានដូចជាតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលការពារផលប្រយោជន៍របស់កូនក្តីរបស់ពួកគេ និងគាំទ្រការចោទប្រកាន់ នៅតែតម្រូវឱ្យមានការអះអាងបញ្ជាក់"។

ថាប្រព័ន្ធបារាំង និងប្រព័ន្ធតុលាការទាំងឡាយដូចជាប្រព័ន្ធតុលាការកម្ពុជាជាដើមយកតាមគំរូបារាំង បានផ្តល់នូវឧទាហរណ៍ទូលំទូលាយគួរសមដែរអំពីការចូលរួមដ៏ជោគជ័យរបស់ជនរងគ្រោះ"[28]។ នៅប្រទេសកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមក្នុងដំណើរការនីតិវិធីដើម្បីទទួលបានសំណងចំពោះព្យសនកម្ម "ដែលជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ឬជាព្យសនកម្មផ្ទាល់ខ្លួន ដែលបានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន ។ ព្យសនកម្មនេះ អាចជាការខូចខាតខាងសម្ភារៈ ឬរាង្គកាយ ឬផ្លូវចិត្ត"[29]។

១៩. នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ "កាលណាផលប្រយោជន៍បុគ្គលរបស់ជនរងគ្រោះរងការប៉ះពាល់ តុលាការត្រូវអនុញ្ញាតឱ្យគេ បញ្ចេញ បង្ហាញ និងពិចារណានូវទស្សនៈ និងកង្វល់របស់ពួកគេក្នុងដំណាក់កាលនៃនីតិវិធីជំនុំជម្រះរឿងក្តីដែលត្រូវតុលាការកំណត់ថាសមស្រប និងក្នុងលក្ខណៈមួយដែលមិនមានលក្ខណៈអនាគតិ ឬមិនមានលក្ខណៈមិនសមស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះដោយយុត្តិធម៌ និងឥតលម្អៀង"[30]។ មេធាវីរបស់ជនរងគ្រោះ ត្រូវតែសុំការអនុញ្ញាតដើម្បីសាកសួរសាកស្សី ។ បន្ទាប់មកទើបអង្គជំនុំជម្រះតម្រូវឱ្យមេធាវីដាក់សំណួរជាមុន ហើយចែកចំណួរនេះទៅព្រះរាជអាជ្ញា និងក្រុមការពារក្តីឱ្យបានដឹងផង។ អង្គជំនុំជម្រះក៏អាចកំណត់លក្ខណៈ និងលំដាប់លំដោយដែលត្រូវសួរសំណួរទាំងនេះផងដែរ ហើយអង្គជំនុំជម្រះក៏អាចសួរសំណួរទាំងនេះជំនួសមុខឱ្យមេធាវីតំណាងជនរងគ្រោះផងដែរ[31]។

២០. ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Katanga[32] នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការបានគូសបញ្ជាក់ថា៖ "នៅពេលតុលាការជឿជាក់ថាការអន្តរាគមន៍ពីអ្នកតំណាងផ្នែកច្បាប់ មិនពាក់ព័ន្ធទៅនឹងផលប្រយោជន៍បុគ្គលរបស់ជនរងគ្រោះណាមួយដែលបានការពារដោយមេធាវី នោះតុលាការមិនអាចអនុញ្ញាតឱ្យមានការអន្តរាគមន៍ឡើយ[33]។ បន្ទាប់មកតុលាការ នឹងបង្ហាញសេចក្តី

---

[28] McGonigle, នៅទំព័រទី១៣៨។

[29] CPC,មាត្រា១៣។

[30] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា៦៨(៣)។

[31] វិធាននីតិវិធី និងភស្តុតាងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ, វិធាន៩១(៣)។

[32] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Katanga & Ngudjolo Chui*, ICC-01/04-01/07, សាលដីកាលើបែបបទនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសវនាការជំនុំជម្រះ, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០។

[33] ដូចជើងទំព័រខាងលើ,កថាខណ្ឌទី៥៨។

ណែនាំលម្អិតពីបែបបទនៃការចូលរួមរបស់របស់ជនរងគ្រោះ[34]" ។

២១. សម្រាប់គោលបំណងបញ្ជាក់ពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីការពារសិទ្ធិជាសារវ័ន្ត របស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មេធាវីការពារក្ដីសូមស្នើថា ការលើកឡើងខាងក្រោមនេះត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង និងលើកមក ពិភាក្សានៅកិច្ចប្រជុំរៀបចំរៀបសវនាការនៅពេលខាងមុខនេះ៖

- ដាក់កម្រិតការអន្តរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលចូលរួមចំណែក ក្នុងការស្វែងរកការពិត ។
- ដាក់កម្រិតការអន្តរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលពាក់ព័ន្ធទាំង ការចោទប្រកាន់ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសម្រាប់តែ គោលបំណងនៃការបង្កើតភស្តុតាងដែលបញ្ជាក់ពីព្យសនកម្ម ។
- ដាក់កម្រិតការអន្តរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលមិនស្រប ជាមួយ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជម្រះក្ដីដោយយុត្តិធម៌ និង ឥតលម្អៀង ។
- ដាក់កម្រិតការអន្តរាគមន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីលើបញ្ហានានា ដែលនឹងមិនបង្កើត ផលប៉ះពាល់ជាអវិជ្ជមានលើការពន្លឿនដំណើរការនីតិវិធី ។
- រឹតត្បិតដល់ដើមបណ្ដឹងរដ្ឋប្បវេណីពីការធ្វើសេចក្ដីសន្និដ្ឋានស្ដីពីការផ្ដន្ទាទោស និង
- រឹតត្បិតដល់ដើមបណ្ដឹងរដ្ឋប្បវេណីពីការសាកសួរសាក្សី អ្នកជំនាញ ឬ ជនជាប់ចោទ ពីអត្តចរិតរបស់ជនជាប់ចោទ សម្រាប់គោលបំណងនៃការផ្ដន្ទាទោស ។

## III. **សំណើសុំ**

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលទាំងអស់ដែលបានបញ្ជាក់នៅទីនេះ និងសម្រាប់គោលបំណង នៃការពារសិទ្ធិជាសារវ័ន្តរបស់លោក អៀង សារី ក្នុងការទទួលបានសមភាពនៃមធ្យោបាយតទល់ក្ដី និងការជំនុំជម្រះក្នុងពេលវេលាសមរម្យ មេធាវីការពារក្ដីស្នើដោយគោរពសុំអង្គជំនុំជម្រះសាលាដំបូង អនុម័តការណែនាំ ដើម្បីបញ្ជាក់ពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

---

[34] ដូចដើងទំព័រខាងលើ,ទំព័រទី២៥ ដល់២៨។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**